ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

លេខាធិការដ្ឋាន

លេខ ៣៤៦ឧ.ក្រ.ច-២០០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

**ផ្ញើចាប់ជូន**

**លោក លោកស្រី ប្រធានតុលាការខេត្ត ក្រុង និងចៅក្រមទាំងអស់**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការអនុវត្តន៍នីតិវិធីនៃការជំនុំជម្រះ ។

លេខាធិការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សូមជម្រាបលោក លោកស្រីថា តាមការចុះពិនិត្យទៅតាមតុលាការខេត្ត-ក្រុងមួយចំនួន និងការពិនិត្យករណីមួយចំនួនរបស់សម័យប្រជុំក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សង្កេតឃើញមានភាពមិនប្រក្រតីមួយចំនួនក្នុងការអនុវត្តន៍នីតិវិធីក្នុងការជំនុំជម្រះដូចជា៖

-ចៅក្រមជំនុំជម្រះមួយចំនួនមិនបានយកចិត្តទុកដាក់ ដាក់កម្មវិធីជំនុំជម្រះឱ្យបានទាន់ពេលវេលានូវសំណុំរឿង ដែលចៅក្រមស៊ើបអង្កេតបានបញ្ជូនមកឱ្យជំនុំជម្រះ ដែលជាហេតុធ្វើឱ្យថេរវេលានៃការឃុំខ្លួនជាបណ្ដោះអាសន្ន ឬ រឿងក្ដីអូសបន្លាយ ឬ ហួសការកំណត់ច្បាប់ ។

-ចៅក្រមជំនុំជម្រះមួយចំនួននៅពេលបញ្ចប់ដំណាក់កាលសួរដេញដោល ការសន្និដ្ឋានទោស និងការសន្និដ្ឋានការពារខ្លួនចប់សព្វគ្រប់ហើយ មិនបានប្រកាសផ្អាកសវនាការ ដើម្បីថយខ្លួនទៅពិចារណា ឬ ថយខ្លួនទៅបន្ទប់សម្ងាត់ ដើម្បីរៀបចំតាក់តែងសេចក្ដីសម្រេចនៃសាលក្រមទេ គឺប្រកាសសាលក្រមនៅពេលជំនុំជម្រះសម្រេចតែម្ដង ហាក់ដូចជាសាលក្រមនោះបានរៀបចំទុកជាមុនជាស្រេចមុននឹងប្រកាសបើកសវនាកា ។

-ចៅក្រមជំនុំជម្រះមួយចំនួនទៀត ក្រោយពីបញ្ចប់ដំណាក់កាលសួរដេញដោល ការសន្និដ្ឋានទោស សន្និដ្ឋានការពារហើយ បានប្រកាសលើកការប្រកាសសាលក្រមទៅថ្ងៃក្រោយ ហើយក្នុងអំឡុងពេលនោះបែរជាធ្វើការស៊ើបអង្កេតបន្ថែមដោយខ្លួនឯងលើគ្រប់ចំណុច ដែលចៅក្រមស៊ើបអង្កេតបានអង្កេតរួចហើយនោះ ។

ចំណាត់ការដូចរៀបរាប់ខាងលើ គឺជាការរំលោភទៅនឹងបទបញ្ញត្តិនៃមាត្រា ១៤១-១៤៥-១០៧ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ និងសារាចរលេខ០៤ សរច ៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៨ ស្ដីពីការណែនាំអំពីនីតិវិធីរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌ ។

សេចក្ដីដូចជម្រាបខាងលើ សូមលោក លោកស្រី ពិនិត្យពិចារណា និងខិតខំអនុវត្តនីតិវិធីជំនុំជម្រះ ឱ្យបានត្រឹមត្រូវតាមការកំណត់នៃច្បាប់ ។

សូមលោក លោកស្រី ទទួលនូវសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២

**វៀល មួន**

ចម្លងជូន

-ប្រធានតុលាការកំពូល
-អគ្គព្រះរាជអាជ្ញាស្ដីទីនៃមហាអយ្យការអមតុលាការកំពូល
-ប្រធានសាលាឧទ្ធរណ៍
-អង្គព្រះរាជអាជ្ញានមហាអយ្យការអមសាលាឧទ្ធរណ៍
-ដើម្បីជូនជ្រាបជាព័ត៌មាន